**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានរតនាគារជាតិ**
**នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ**

**សូមគោរពជូន**
**ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ**

**I-លទ្ធផលការងារដែលបានអនុវត្តក្នុងខែធ្នូ ឆ្នាំ២០១៦÷**

អគ្គនាយកដ្ឋានរតនាគារជាតិបានអនុវត្តការងារក្នុងខែធ្នូ ឆ្នាំ២០១៦ មួយចំនួនដូចខាងក្រោម÷

១-បានជំរុញលើការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ របបសន្តិសុខសង្គមរបស់និវត្តជន(បជស) និងបេឡាជាតិអតីតយុទ្ធជន(បជអ) បានទាន់ពេលវេលា។

២-បានបន្តសហការជាមួយនាយកដ្ឋានព័ត៌មានវិទ្យា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការងារបច្ចេកទេសផ្សេងៗ ជាពិសេសបន្តពិនិត្យពិភាក្សានិងជំរុញតាមដានលើការងាររៀបចំរបាយការណ៍ និងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងដំណើរការប្រព័ន្ធ FMIS ដើម្បីគាំទ្រដល់ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។

៣-បានចូលរួមកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា ស្តីពីសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ដោយសេចក្តីព្រាងច្បាប់នេះ ត្រូវបានពិនិត្យសម្រេចអនុម័ត ក្នុងសម័យប្រជុំពេញអង្គព្រឹទ្ធសភា កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦។

៤-បានចូលរួមកិច្ចប្រជុំពេញអង្គរដ្ឋសភានិងពេញអង្គព្រឹទ្ធសភា ស្តីពីសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ដោយសេចក្តីព្រាងច្បាប់នេះ ត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៦ និងត្រូវបានព្រឹទ្ធសភាអនុម័តកាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦។

៥-បានចូលរួមធ្វើបទបង្ហាញ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាលក្នុងវគ្គបណ្តុះបណ្តាលស្តីពី "ការអនុវត្តនីតិវិធីប្រព័ន្ធហិរញ្ញវត្ថុ" ជូនដល់និយ័តករទូរគមនាគមន៍កម្ពុជានៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

៦-បានចូលរួមសិក្ខាសាលាបញ្ជ្រាបចំណេះដឹងស្តីអំពី "ការព្យាករណ៍ចំណូល" ដល់បណ្តាអង្គភាពប្រមូលចំណូល។

៧-បានបន្តប្រជុំណែនាំនិងបណ្តុះបណ្តាលមន្ត្រីជំនាញទទួលបន្ទុកពិនិត្យការអនុវត្តចំណាយថវិកា ស្តីពីលិខិតបទដ្ឋានគតិយុត្តដែលបានធ្វើបច្ចុប្បន្នភាពថ្មីៗ និងចំណុចសំខាន់ៗពាក់ព័ន្ធនឹងការត្រួតពិនិត្យការចំណាយថវិកាតាមប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដើម្បីពង្រឹងគុណភាព ប្រសិទ្ធភាព ក្នុងការត្រួតពិនិត្យអាណត្តិបើកប្រាក់ និងលិខិតយុត្តិការចំណាយ ដើម្បីទូទាត់ចំណាយថវិកាឱ្យបានទាន់ពេលវេលា ហើយបានត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ។

៨-បានបន្តណែនាំនិងជំរុញក្រសួង ស្ថាប័នថវិកាកម្មវិធីជាពិសេសអង្គភាពថវិកា ឱ្យប្រញាប់ប្រមូលសក្ខីបត្រចំណាយនិងបោះផ្សាយអាណត្តិនិយ័តកម្មទូទាត់បំពេញបេឡារជ្ជទេយ្យបុរេប្រទាន ឱ្យបានទាន់ពេលវេលាតាមកាលបរិច្ឆេទកំណត់។

៩-បានចូលរួមធ្វើបទបង្ហាញ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់គ្រឹះស្ថានសាធារណៈ

រដ្ឋបាល។

១០-បានបន្តចូលរួមប្រជុំពិភាក្សា លើការងារធ្វើបច្ចុប្បន្នភាពមាតិកាថវិកា និងប្លង់គណនេយ្យសម្រាប់ថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

១១-បានចូលរួមប្រជុំពិនិត្យនិងពិភាក្សា លើរបៀបវារៈនៃសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ និងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

១២-បានចូលរួមប្រជុំពិនិត្យនិងពិភាក្សាអំពីកាតព្វកិច្ចបង់បំណុលថ្លៃសួយសារសាច់ដី និងខ្សាច់ជូនរដ្ឋ ។

១៣-បានចូលរួមប្រជុំពិភាក្សា ស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៦។

១៤-បានចូលរួមប្រជុំពិភាក្សា លើសេចក្តីព្រាងគោលការណ៍ណែនាំ ស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់រដ្ឋបាលរាជធានី ខេត្ត។

១៥-បានចូលរួមសិក្ខាសាលាស្តីអំពីការធ្វើ “ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល TOFE/GFS”។

១៦-បានបន្តសហការជាមួយក្រសួង ស្ថាប័នថវិកាកម្មវិធីក្នុងការដោះស្រាយបញ្ហាប្រឈម ដែលពាក់ព័ន្ធនឹងការអនុវត្តចំណាយថវិកា ជាពិសេសលើការអនុវត្តចំណាយរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធី ក្នុងឆ្នាំថវិកា២០១៦។

១៧-បានខិតខំរៀបចំបូកសរុបនិងផ្ទៀងផ្ទាត់តួលេខអនុវត្តចំណូល ចំណាយថវិកាប្រចាំឆ្នាំ២០១៦ជាបណ្តើរៗ ដើម្បីធ្វើយ៉ាងណាឱ្យការបូកបញ្ជីចំណូល ចំណាយថវិកាឆ្នាំ២០១៦ នោះត្រឹមត្រូវនិងបានទាន់ពេលវេលា។

១៨-បានរៀបចំសេចក្តីណែនាំលេខ ៨៩៣៨ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបិទបញ្ជីគណនេយ្យថវិកា រដ្ឋបាលថ្នាក់ជាតិ និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៦ និងទិសដៅអនុវត្តឆ្នាំ២០១៧។

១៩-បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបិទបញ្ជីគណនេយ្យថវិការដ្ឋបាលថ្នាក់ជាតិ និងថវិការដ្ឋបាលថ្នាក់ ក្រោមជាតិឆ្នាំ២០១៦ និងទិសដៅអនុវត្តឆ្នាំ២០១៧។

២០-បានបើកវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន និងកិច្ចបញ្ជិកាគណនេយ្យរជ្ជទេយ្យបុរេប្រទាន ដល់រជ្ជទេយ្យករបុរេប្រទាន និងគណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល។

២១-បានបើកវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីគ្រប់គ្រងរជ្ជទេយ្យចំណូលដល់រជ្ជទេយ្យករចំណូល និងគណ-នេយ្យករ ប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល។

២២-បានបើកវគ្គបណ្តុះបណ្តាល ស្តីពីគណនេយ្យទូទៅរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដល់គណនេយ្យករ និងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

២៣-បានរៀបចំប្រកាសលេខ ១៤៦៩ សហវ.ប្រក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការលុបការកែសម្រួល និងការបង្កើតបន្ថែមគណនីនិងអនុគណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

២៤-បានចូលរួមធ្វើបទបង្ហាញនៅខេត្តព្រះសីហនុ ស្តីពីលទ្ធផលការងារសម្រេចបានក្នុងឆ្នាំ២០១៦ បញ្ហាប្រឈម និងទិសដៅអនុវត្តឆ្នាំ២០១៧។

២៥-បានរៀបចំលិខិតលេខ ៩០៩១ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការអនុញ្ញាតឱ្យធនាគារកាណាឌី-យ៉ា ក.អ ទទួលការបង់សាច់ប្រាក់ ឬបង្វែរប្រាក់ចូលគណនីរបស់អគ្គនាយកដ្ឋានរតនាគារជាតិ នៅធនាគារកាណា-ឌីយ៉ា ក.អ ក្នុងថ្ងៃទី២៩-៣០ ខែធ្នូ ឆ្នាំ២០១៦នេះ ដើម្បីសម្រួលដល់ក្រសួង ស្ថាប័ន អង្គភាព ក្នុងពេលដែលធនាគារជាតិ នៃកម្ពុជា ឈប់សម្រាកដើម្បីបិទបញ្ជីនៅចុងឆ្នាំ។

២៦-បានប្រជុំកែសម្រួលឡើងវិញលើសេចក្តីណែនាំលេខ ១៦៤៦សហវ.ប្រក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដើម្បីឱ្យសមស្របតាមការអនុវត្តបច្ចុប្បន្ន។

២៧-បានចូលរួមប្រជុំក្រុមប្រឹក្សាភិបាលមន្ទីរពេទ្យព្រះកុសុមៈ នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦។

២៨-បានរៀបចំប្រកាសលេខ ១៥៨៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការកែសម្រួលប្រការ ១៣ នៃប្រកាសលេខ ២៧៥ សហវ.ប្រក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេ-ប្រទានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

២៩-អធិការកិច្ចរតនាគារ បានចុះពិនិត្យកិច្ចបញ្ជិកាគណនេយ្យការិយបរិច្ឆេទ២០១៥ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅរតនាគារខេត្តកំពង់ចាម រតនាគារខេត្តកំពង់ធំ រតនាគារខេត្តកណ្តាល និងរតនាគារខេត្តត្បូងឃ្មុំ។

៣០-គណៈកម្មការជម្រះចោលឯកសារអស់សុពលភាពប្រើប្រាស់ បានដុតដុតកម្ទេចឯកសារឆ្នាំ២០០៤ នៅអគ្គនាយកដ្ឋានរតនាគារជាតិ។

## II-ទិសដៅសម្រាប់អនុវត្តការងារខែមករា ឆ្នាំ២០១៧÷

អគ្គនាយកដ្ឋានរតនាគារជាតិមានទិសដៅសម្រាប់អនុវត្តការងារខែមករា ឆ្នាំ២០១៧មានដូចខាងក្រោម÷

១-ត្រូវបន្តជំរុញលើការបើកផ្តល់ប្រាក់បៀវត្ស ជូនមន្ត្រីរាជការនិងកងកម្លាំងប្រដាប់អាវុធឱ្យបានទាន់ក្នុងខែ។

២-ត្រូវបន្តសហការជាមួយក្រសួង ស្ថាប័នថវិកាកម្មវិធីក្នុងការដោះស្រាយបញ្ហាប្រឈម ដែលពាក់ព័ន្ធនឹងការអនុវត្តចំណាយថវិកា ជាពិសេសណែនាំនិងជំរុញការអនុវត្តចំណាយរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធី ក្នុងឆ្នាំថវិកា ២០១៦ ឱ្យមានដំណើរការរលូន និងបានត្រឹមត្រូវស្របតាមនីតិវិធីហិរញ្ញវត្ថុ។

៣-ត្រៀមចូលរួមធ្វើបទបង្ហាញក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការរៀបចំថវិកានិងនីតិវិធីអនុវត្តថវិកាកម្មវិធី ដល់ក្រសួង ស្ថាប័ន ដែលនឹងចាប់ផ្តើមអនុវត្តថវិកាកម្មវិធីក្នុងឆ្នាំថវិកា២០១៧នេះ។

៤-ត្រូវខិតខំរៀបចំផ្ទៀងផ្ទាត់តួលេខអនុវត្តចំណូល ចំណាយថវិកា ដើម្បីអាចបូកសរុបបញ្ជីចំណូល ចំណាយថវិកា ប្រចាំឆ្នាំ២០១៦នេះ ជាបណ្តោះអាសន្ន។

៥-ត្រូវបន្តរៀបចំតារាងឧបសម្ព័ន្ធចំណូល ចំណាយថវិកាជាបណ្តើរៗ សម្រាប់បម្រើដល់ការងាររៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦។

៦-ត្រូវខិតខំបំប៉នសមត្ថភាពការងាររបស់មន្ត្រីជំនាញ លើការត្រួតពិនិត្យការអនុវត្តចំណាយថវិកា ឱ្យបានត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ និងស្របតាមបច្ចុប្បន្នភាពនៃលិខិតបទដ្ឋានគតិយុត្តិ។

៧-បន្តកែសម្រួលសេចក្តីណែនាំលេខ ១៦៤៦ សហវ.ប្រក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១២ ស្តីពីការកំណត់ លិខិតយុត្តិការចំណាយមូលនិធិគាំទ្រការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា ទារក មតេយ្យសហ-គមន៍ ទឹកស្អាត និងអនាម័យ សមភាពយេនឌ័រ កិច្ចការពារកុមារ ការចុះបញ្ជីអត្រានុកូលដ្ឋាន ការលើកកំពស់ថែទាំ ការអភិវឌ្ឍកុមារតូច និងការរៀបចំដោះស្រាយគ្រោះមហន្តរាយនៅឃុំ សង្កាត់ ឱ្យស្រមតាមការអនុវត្តនាពេលបច្ចុប្បន្ន។

៨-រៀបចំប្លង់គណនេយ្យរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍកសិកម្មកម្ពុជា សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យសុខាភិបាល និងវិទ្យាស្ថានជាតិសុខភាពសាធារណៈ។

៩-ត្រូវរៀបចំលិខិតឆ្លើយតប ទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការស្នើសុំអនុញ្ញាតឱ្យបេឡាជាតិអតីតយុទ្ធជន (ប.ជ.អ) រក្សាទុកគណនីនៅធនាគារអេស៊ីលីដា និងនៅធនាគារកាណាឌីយ៉ា ក.អ ។

១០-ត្រូវរៀបចំលិខិតស្នើសុំគោលការណ៍បិទគណនីប្រាក់បញ្ញើថវិការបស់សាលារាជធានីភ្នំពេញ សម្រាប់គម្រោង ដោយប្រើតែគណនីតែមួយ។

១១-ត្រូវណែនាំនីតិវិធីជម្រះបុរេប្រទានរបស់គ្រឹះស្ថានអង្គរ ចំនួន ១០.១៧៧.៧៤៣.៦០០រៀល ឱ្យបានជ្រះស្រឡះ។

១២-ត្រូវបន្តការជួយតម្រង់ទិសដល់គ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងការអនុវត្តគោលការណ៍គណនេយ្យសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

១៣-អធិការកិច្ចរតនាគារ ត្រូវចុះត្រួតពិនិត្យការងាររបស់រតនាគាររាជធានី ខេត្តជាបន្តបន្ទាប់ទៀត។

១៤-គណៈកម្មការជម្រះចោលឯកសារអស់សុពលភាពប្រើប្រាស់ ត្រូវបន្តចុះដុតកម្ទេចឯកសារឆ្នាំ២០០៥ នៅតាមបណ្តារតនាគារខេត្តជាបន្តទៀត។